# រួមជួយគ្នាជញ្ជាត់ព្រលឹងជាតិខ្មែរ

ដោយ **សេង សុផ័ណ** ហៅ **តត្តី**

## សេចក្តីផ្តើម

ជញ្ជាត់ព្រលឹងខ្មែរកើតឡើងពីគំនិតចង់ប្រមូលផ្តុំឡើងវិញនូវយោនិសោមនសិការនិងសេចក្តីស្នេហាចំពោះជាតិមាតុភូមិ។ តាមពិត តាមការស្រាវជ្រាវរបស់នរវិទ្យានិងបុរាណវិទ្យា ពិធីជញ្ជាត់ព្រលឹងជាពិធីកម្មមួយដែលប្រជាជនខ្មែរបដិបត្តិយូរលង់ណាស់មកហើយ។ តាមការស្រាវជ្រាវបញ្ជាក់ថា នៅពេលមានមនុស្សឈឺថ្កាត់ដោយជំងឺផ្សេងៗ ក្រុមគ្រួសារនិងញាតិមិត្តតែងធ្វើពិធីជញ្ជាត់ព្រលឹងដើម្បីព្យាបាលនិងដេញភូតព្រាយបីសាចអោយចេញពីកាយ–ចិត្តរបស់អ្នកជំងឺ។ តាមការសង្កេតរបស់អ្នកស្រាវជ្រាវ ពិធីកម្មនេះមិនមានភស្តុតាងជាវិទ្យាសាស្ត្រជាក់ច្បាស់ថាមានលទ្ធភាពអាចព្យាបាលជំងឺនោះទេ តែជាពិធីល្អមួយអាចជួយពង្រឹងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវវិញ្ញាណរបស់អ្នកជំងឺ។

លស់ព្រលឹង បាត់ព្រលឹង ភ័ន្តថយស្មារតីព្រោះភ្ញាក់ឬភ័យតក់ស្លុតរន្ធត់ខ្លាំង ជាហេតុផលធំៗដើម្បីអោយមានការហៅព្រលឹងមកវិញ ដែលជាទូទៅចាស់បុរាណខ្មែរហៅថាបបក់ព្រលឹង បញ្ជាប់ព្រលឹង ឬជញ្ជាត់ព្រលឹង។

តាមតថភាពជាក់ស្តែងនៃពិធីជញ្ជាត់ព្រលឹងនេះ ជញ្ជាត់ព្រលឹងជាតិខ្មែរគឺជាការស្រាវជ្រាវរកសច្ចភាពពិតនៃវិបាកកម្មរបស់កម្ពុជា (ទុក្ខសច្ចៈ) ដើមហេតុនៃវិបាកកម្មទាំងឡាយនោះ (សមុទយសច្ចៈ) វិបាកកម្មទាំងនោះអាចទប់ស្កាត់និងដោះស្រាយបាន (និរោធសច្ចៈ) ហើយស្វែងរកវិធីដែលល្អបំផុតដើម្បីការទប់ស្កាត់និងការដោះស្រាយរហូតអាចទទួលបានជោគជ័យ (មគ្គសច្ចៈ)។

## ព្រលឹងគឺជាអ្វី?

ព្រលឹង តាមនិយមន័យទូទៅដែលប្រជាជនខ្មែរយល់ទាំងអស់គ្នាសំដៅទៅលើសភាវៈវិញ្ញាណរបស់មនុស្សម្នាក់ៗ ហើយពួកគេយល់ថាពេលមនុស្សស្លាប់ទៅព្រលឹងរមែងសល់នៅដើម្បីទៅចាប់ភពថ្មីផ្សេងៗ។ វចនានុក្រមខ្មែរខ្លះអោយនិយមន័យព្រលឹងថាជាដំណើរជីវិត ស្មារតី វិញ្ញាណ សិរីសួស្តី សេចក្តីសុខ សេចក្តីចំរើន។ ឧទាហរណ៍ដូចជាខ្មែរយើងតែងហៅគ្នាជាទំលាប់ថាមាសស្ងួនព្រលឹង កែវព្រលឹង ព្រលឹងមាសបងជាច្រើន។ ឫសគល់នៃពាក្យថាព្រលឹងនេះ មានប្រភពផ្សេងៗគ្នា។ តាមការស្រាវជ្រាវរបស់លោកសាស្ត្រាចារ្យអាំង ជូលាន ព្រលឹងប្រហែលមានឫសគល់មកពីពាក្យថាព្រះលិង្គ ដែលកាលដើមឡើយខ្មែរគោរពសាសនាព្រាហ្មណ៍ លទ្ធិសិវៈ។ ព្រះបាទជ័យវរ្ម័នទី២ មានឈ្មោះល្បីល្បាញសំរាប់លទ្ធិទេវរាជាដែលជាលទ្ធិមួយកើតឡើងពីពិធីកម្មប្រតិស្ថានសិវលិង្គដែលធំជាងគេបំផុតនៅមហេន្ទ្របព្វតាឬភ្នំគូលេន។

តាមលទ្ធិព្រះពុទ្ធសាសនាថេរវាទ ព្រលឹងគឺជាវិញ្ញាណដែលអាចចាប់ភពថ្មីឬកំណើតថ្មីដែលសភាវៈវិញ្ញាណនេះមានការផ្លាស់ប្តូរនិងគ្មានទំរង់ជាអាត្ម័នទេ។ ទ្រឹស្តីនិងគំហើញនេះមានលក្ខណៈខុសពីលទ្ធិព្រហ្មញ្ញសាសនាដែលជឿថាព្រលឹងឬអាត្ម័នជារបស់អមតៈ មិនផ្លាស់ប្តូរ។

សំរាប់សិក្ខាសាលានៅពេលនេះ ព្រលឹងគឺជាហឫទ័យ ស្មារតី បេះដូង វិញ្ញាណ ឬមនសិការរបស់ខ្មែរទាំងអស់ក្នុងការរួបរួមសាមគ្គីគ្នាជាធ្លុងមួយ។ ព្រលឹងទាំងអស់**រួមមាន ព្រលឹងជាតិសាសន៍ខ្មែរ ព្រលឹងវប្បធម៌–ប្រពៃណីយ៍–ទំនៀមទំលាប់–ព្រះពុទ្ធសាសនាខ្មែរ ព្រលឹងសង្គមធម៌ខ្មែរ ព្រលឹងសេដ្ឋកិច្ចខ្មែរ និង ព្រលឹងនយោបាយខ្មែរ។**

យ៉ាងហោចណាស់មានព្រលឹងសំខាន់ពីរយ៉ាងដែលយើងត្រូវជួយគ្នាបបក់ឬជញ្ជាត់គឺព្រលឹងអតីតកាលដូចជាភាសា របាំតូរតន្ត្រី និងវប្បធម៌ផ្សេងៗ និងព្រលឹងសម័យទំនើបគឺការអភិវឌ្ឍន៍គ្រប់ផ្នែកដើម្បីរត់អោយទាន់ពិភពលោកបច្ចុប្បន្ន។ អតីតកាលខ្លះ យើងមិនអាចធ្វើបានដូចបុព្វបុរសខ្មែរយើងទេ ឧទាហរណ៍ដូចជាយើងមិនអាចកសាងប្រាសាទអង្គរវត្តដូចបុព្វបុរសយើងទេ។ ដូចគ្នាដែរបច្ចុប្បន្ននិងអនាគតកាលខ្លះ យើងនៅដើរមិនទាន់គេទេ ដូចជាព្រះសង្ឃក្នុងព្រះពុទ្ធសាសនាខ្មែរត្រូវងាកទៅរកកិច្ចការសង្គមអោយបានច្រើន របបនយោបាយប្រជាធិបតេយ្យខ្មែរនាពេលបច្ចុប្បន្ននៅមានលក្ខណៈមិនមែនប្រជាធិបតេយ្យពិតប្រាកដឡើយ ហើយតុលាការឯករាជ្យនៅមិនទាន់ត្រូវបានបដិបត្តិនៅប្រទេសកម្ពុជានៅឡើយដែរ។

## ជាតិគឺជាអ្វី?

ជាតិតាមទ្រឹស្តីព្រះពុទ្ធសាសនាមានន័យថាកំណើត។ ន័យទូទៅមួយទៀត ប្រជាជនខ្មែរយើងនិយមប្រើពាក្យថារស់ជាតិ ឬជាតិសម្លជាដើម។ តែជាតិនៅទីនេះ យើងសង្កត់ធ្ងន់ទៅលើជាតិមាតុភូមិ។ ជាតិតាមនិយមន័យបច្ចឹមប្រទេសសម័យទំនើបសំដៅទៅលើអង្គប្រកបដូចជាមានភាសា មានវប្បធម៌ មានសាសនា មានតំលៃរួម មានជាតិសាសន៍ មានប្រជាជន មានដែនដីរបស់ខ្លួន មានអធិបតេយ្យភាពដែលធានាដោយច្បាប់អន្តរជាតិ និងមានប្រព័ន្ធការគ្រប់គ្រងដើម្បីធានានូវសិទ្ធិសេរីភាពនិងសុខមាលភាពប្រជាជន។

អ្នកប្រាជ្ញខាងវិទ្យាសាស្រ្តនយោបាយបានអោយនិយមន័យក្នុងការកកើតជាតិ (formation of nation-state) ខុសៗគ្នា។ អ្នកស្រីបណ្ឌិតហ្វូហ្គាវីន ម៉ាហ្គារេតសរសេរថា "ជាតិនិយម" គឺជាគន្លឹះនៃការកកើតជាតិ ហើយជាតិនិយមនេះកើតពីតំលៃនិងជំនឿរួមរបស់ប្រជាជនទាក់ទងនឹងប្រវត្តិសាស្រ្ត រឿងព្រេងនិទាន ឬវប្បធម៌ប្រពៃណីយ៍ព្រមទាំងសាសនា។ តែអ្នកស្រីបដិសេធន៍នូវគំនិតជាតិនិយមជ្រុល។ សំរាប់សាស្រ្តាចារ្យធីលលី ឆាល ការកកើតជាតិរមែងប្រមូលផ្តុំឡើងពីការប្រកួតប្រជែងជាមួយបណ្តាប្រទេសខាងក្រៅជិតខាង។ លោកសង្កត់ទៅលើការខិតខំធ្វើអោយប្រទេសជិតខាងចុះទន់ខ្សោយជាចំណុះរបស់ខ្លួន ការខិតខំត្រួតត្រាប្រទេសជិតខាងរួចបំបាត់ជាតិនោះចោល ឬការខិតខំប្រឹងប្រែងធ្វើអោយមានតុល្យភាពលំនឹងខាងទំនាក់ទំនងប្រកបដោយភាតរភាពជាដើម។ ចំណែកឯអ្នកស្រីស្កុកប៉ុល ធេដា បានយកគំនិតចលនាតស៊ូ

វណ្ណៈជាគន្លឹះឈានទៅរកការរួបរួមបង្កើតជាជាតិឡើង។ ការតស៊ូរើបំរាស់របស់វណ្ណៈកម្មករនិងកសិករគឺជាចលករនាំអោយមានការផ្សះផ្សារគ្នាក្រោមច្បាប់និងការដឹកនាំប្រកបដោយសមភាពនិងយុត្តិធម៌។

អ្នកស្រីសាស្ត្រាចារ្យអេដវ៉ាដ ផេនឌី នៅក្នុងសៀវភៅស្តីអំពី"កម្ពុជា: ការស្ថាបនាជាតិរវាងឆ្នាំ ១៨៦០-១៩៤៥" បានសរសេរថាការឈានជើងមកដល់របស់អាណានិគមនិយមបារាំងបានធ្វើអោយមានការផ្លាស់ប្តូរនៅកម្ពុជាជាច្រើនជាពិសេសការកកើតរូបរាងនូវជាតិមាតុភូមិតាមរយៈភាសា វប្បធម៌ បុរាណ ប្រាសាទនិងសាសនា ដែលទាំងនេះគឺជាអង្គប្រកបសំខាន់ក្នុងការរក្សាអត្តសញ្ញាណជាតិ។

នៅក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជជួន ណាត ជាតិសំដៅទៅលើកំណើត ឬមនុស្សដែលមានសញ្ជាតិផ្សេងគ្នាដូចជាជាតិខ្មែរ ជាតិចិន ជាដើម។

**សំរាប់អ្នកវិញ តើអ្នកយល់យ៉ាងណា?**

**ហើយតើមួយណាសំខាន់ជាង? ចូរគូរង្វង់មូលនៅលើលេខនោះ**

## ព្រលឹងជាតិសាសន៍ខ្មែរ

១. ខ្មែរនៅគ្រប់ទីកន្លែង ទោះបីជាខ្មែរលើ ខ្មែរកណ្តាល ខ្មែរក្រោម ខ្មែរនៅបរទេសទាំងអស់ពួកគេគឺជាខ្មែរ ដែលយើងត្រូវតែស្រឡាញ់រាប់អាន ជួយជ្រោមជ្រែងគ្នា និងរួបរួមគ្នា។

២. ក្នុងយុគសម័យសកលភាវូបនីយកម្ម លំហូរចូលនៃសារពត៌មាន វប្បធម៌ និងអន្តោប្រវេសន៍គឺជារឿងដែលជៀសវាងមិនបាន ប៉ុន្តែរដ្ឋាភិបាលកម្ពុជាត្រូវតែធ្វើអោយប្រាកដថាអន្តោប្រវេសន៍ដែលហូរចូលមកក្នុងប្រទេសកម្ពុជាត្រូវតែមានច្បាប់ទំលាប់ត្រឹមត្រូវ ហើយត្រូវធ្វើអោយប្រាកដថាអ្នកទាំងនោះបានចូលសញ្ជាតិខ្មែរនិងបំរើផលប្រយោជន៍ខ្មែរបានច្បាស់លាស់ ជាពិសេសបានធ្វើសញ្ជាតូបនីយកម្មនិងសមាហរណីយកម្មដូចប្រទេសជឿនលឿនទាំងឡាយមានអាមេរិកនិងកាណាដាជាជាដើម ទើបគេអាចរស់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជាបាន។

៣. អ្នកណាក៏ដោយ ទោះបីមានសាច់ឈាមជាខ្មែរក្តី ឬមានសាច់ឈាមមិនមែនជាខ្មែរក្តី បើគេមានសេចក្តីស្រឡាញ់ខ្មែរឬធ្វើគុណូបការៈសំរាប់ខ្មែរប្រកបដោយទឹកចិត្តស្មោះត្រង់ យើងទាំងអស់គ្នាចាត់ទុកថាពួកគេគឺជាអ្នកមានគុណូបការគុណម្នាក់សំរាប់ជាតិខ្មែរ។

៤. គាំទ្រមតិទាំងបីខាងលើ

៥. មតិផ្ទាល់របស់អ្នក.............................................................................
.............................................................................................
.............................................................................................
.............................................................................................
.............................................................................................

## ព្រលឹងវប្បធម៌_ប្រពៃណីយ៍_ទំនៀមទំលាប់_ព្រះពុទ្ធសាសនាខ្មែរ

១. ព្រះសង្ឃដែលបដិបត្តិត្រឹមត្រូវតាមពុទ្ធបញ្ញត្តិ តាមវិន័យ និងដាក់ព្រះកាយរួមសុខរួមទុក្ខជាមួយប្រជាជន មិនប្រឡូកច្រប្លូកច្របល់ជាមួយនយោបាយលោកីយ៍តែខ្វល់ខ្វាយច្រើនពីនយោបាយពុទ្ធធម៌ គឺជាព្រះសង្ឃគំរូនិងធ្វើអោយព្រះពុទ្ធសាសនារីកចំរើន ។

២. វប្បធម៌មានន័យថាថ្នាលនាំទៅរកភាពរីកចំរើនហើយមានអត្តសញ្ញាណរបស់ខ្លួនច្បាស់លាស់ ។ យើងមិនអាចទប់លំហូរយ៉ាងកំហុកនៃសកលភាវូបនីយកម្មបានទេ តែយើងអាចកែច្នៃអោយមានតំលៃនិងមានលក្ខណៈជាខ្មែរពិតប្រាកដ ប្រៀបប្រដូចនឹងទឹកហូរចុះពីលើច្រាំងយ៉ាងកំហុក យើងត្រូវបង្ហូរវាអោយចូលក្នុងស្រែឬចូលច្បារដំណាំដើម្បីប្រើប្រាស់អោយកើតប្រយោជន៍ ។

៣. ដើម្បីរក្សានិងផ្សព្វផ្សាយពីប្រពៃណីយ៍ទំនៀមទំលាប់បានល្អ យើងត្រូវសិក្សាអោយយល់ច្បាស់ពីប្រពៃណីយ៍វប្បធម៌ទាំងនោះ ។ ការអប់រំដល់យុវជនតាមរយះសាលារៀននិងដល់ប្រជាជនតាមរយះសារពត៌មានអំពីវប្បធម៌ល្អទាំងវប្បធម៌លើផ្នត់គំនិតនិងវប្បធម៌រូបធម៌ដូចជាពិធីបុណ្យ សិល្បះតូរតន្ត្រីនិងបុរាណស្ថាននានាជាដើម ត្រូវតែមានគោលការណ៍ច្បាស់លាស់មួយ ។

៤. វប្បធម៌កោធញញើត បំរើ គោរព ការពារ ចំពោះចៅហ្វាយនាយដើម្បីបានបុណ្យសក្តិនិងលាភសក្ការៈត្រូវតែបញ្ឈប់ដើម្បីចាប់យកព្រះពុទ្ធធម៌ដែលជាច្បាប់កំពូលនិងការមានសមត្ថភាពព្រមទាំងការព្យាយាមរបស់បុគ្គលម្នាក់ៗជាធំ ។

៥. គាំទ្រមតិទាំង៤ខាងលើ

៦. មតិផ្ទាល់របស់អ្នក.................................................................................

.............................................................................................

.............................................................................................

.............................................................................................

.............................................................................................

## ព្រលឹងសង្គមធម៌ខ្មែរ

១. មនុស្សក្នុងសង្គមត្រូវមានសិទ្ធិសេរីភាព ការឧបត្ថម្ភគាំពារ និងឱកាសក្នុងការអភិវឌ្ឍន៍ជីវិតស្មើភាពគ្នាក្រោមរង្វង់នៃច្បាប់កំពូលតែមួយ ។

២. កុមារ ស្ត្រី ជនពិការ ចាស់ជរា និង ជនទុរគតអនាថា ត្រូវតែទទួលបានការគាំពារជាពិសេសអំពីរដ្ឋ ។

៣. អនាម័យនិងសុខភាពកុមារត្រូវតែពង្រឹង។ បញ្ឈប់អោយបាននូវអំពើហឹង្សាក្នុងគ្រួសារនិងការប្រើប្រាស់ពលកម្មកុមារ។ កូនអាយុពី៤ឆ្នាំឡើងទៅ ឪពុកម្តាយត្រូវបញ្ជូនទៅសាលារៀន បើមិនដូច្នោះ ឪពុកម្តាយឬអាណាព្យាបាលត្រូវប្រឈមចំពោះមុខច្បាប់។

៤. ត្រូវរៀបចំផ្គត់ផ្គង់ជូនប្រាក់ខែគ្រូនិងមន្ត្រីរាជការស៊ីវិលអោយបានសមរម្យដើម្បីផ្គត់ផ្គង់ជីវភាពនិងជៀសវាងការប្រព្រឹត្តអំពើពុករលួយក្នុងសាលារៀនព្រមទាំងសេវាកម្មសាធារណៈដែលជាមេរោគសង្គមគួរអោយស្អប់ខ្ពើមបំផុត។

៥. អ្នកធំ–អ្នកមានអំណាចត្រូវដាក់ខ្លួនអោយទាបជាងប្រជាជន ព្រោះខ្លួនរស់បានដោយសារប្រាក់បៀរវត្សន៍ពីប្រជាជន។ បញ្ឈប់ការប្រើប្រាស់អំណាចក្លែងក្លាយរបស់ខ្លួនទៅគំរាមគំហែងប្រជាជននិងការបំពោងស៊ីរ៉ែនរំខានដល់ប្រជាពលករដែលកំពុងប្រកបមុខរបរចិញ្ចឹមជីវិតពេលធ្វើដំណើរម្តងៗ។ ឡានស៊ីរ៉ែនអាចប្រើលើផ្លូវសាធារណៈបាន មានតែឡានពេទ្យសង្គ្រោះបន្ទាន់និងឡានពន្លត់អគ្គីភ័យតែប៉ុណ្ណោះ។

៦. គាំទ្រមតិទាំង៥ខាងលើ

៧. មតិរបស់អ្នកផ្ទាល់.................................................................................
..............................................................................................................
..............................................................................................................
..............................................................................................................
..............................................................................................................

## ព្រលឹងសេដ្ឋកិច្ចខ្មែរ

១. សម្បត្តិជាតិទាំងឡាយដូចជាទឹក ដី ព្រៃព្រឹក្សា រ៉ែ បុរាណស្ថាន និងចំណូលថវិកាបានមកពីពន្ធអាករនៃក្រុមវិនិយោគិនជាដើម ត្រូវបែងចែកដល់ប្រជាពលរដ្ឋដែលជាម្ចាស់កម្មសិទ្ធិអោយបានស្មើភាពគ្នា។

២. ជំរុញអោយមានការបង្កើនផលិតផលកសិ– ឧស្សាហកម្មអោយបានច្រើន បង្កើតទីផ្សារចែកចាយអោយបានទូលំទូលាយ ដើម្បីតំរូវការទៅនឹងដីស្រែធំល្វឹងល្វើយសំរាប់កសិករជាង៩០ភាគរយ។

៣. សំឡឹងរកជំនាញពិសេសសំរាប់អនាគតកម្ពុជាដែលអាចប្រកួតប្រជែងជាមួយពិភពលោកបាន។ ដោយប្រជាជនកម្ពុជាត្រូវបានគេស្គាល់តាមរយះទេពកោសល្យនៃការច្នៃប្រឌិតនិងប្រកបដោយការស្រមើរស្រម៉ៃ យើងត្រូវអភិវឌ្ឍយុវជនកម្ពុជាអោយពូកែជាងគេផ្នែកពត៏មានវិទ្យានិងប្រព័ន្ធអ៊ិនតើនិតនៅពេលខាងមុខ។

៤. គាំទ្រមតិទាំង៣ខាងលើ

៥. មតិរបស់អ្នកផ្ទាល់.........................................................................
.................................................................................................
.................................................................................................
.................................................................................................
................................................................................................

## ព្រលឹងនយោបាយខ្មែរ

១. លើកទឹកចិត្តទាំងអស់គ្នាជាពិសេសយុវជននិងស្ត្រីអោយចូលរួមសកម្មភាពនយោបាយអោយបានច្រើន ដើម្បីជួយស្រោចស្រង់ខ្លួនឯង ក្រុមគ្រួសារ និងប្រទេសជាតិ។ នយោបាយមិនមែនជារឿងគួរអោយស្អប់ខ្ពើមឬខ្លាចរអារទ្បើយ តែជាការតព្វកិច្ចរបស់ពលរដ្ឋខ្មែរម្នាក់ៗ។

២. សំរាប់ព្រះរាជណាចក្រកម្ពុជា ប្រពន្ឋ័នយោបាយនិងការគ្រប់គ្រងដែលគួរយកគំរូតាមល្អបំផុតគឺយកលំនាំតាមប្រទេសអង់គ្លេស ដែលជាប្រទេសគ្រប់គ្រងដោយស្តេចអមជាមួយនាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីមានសិទ្ធិត្រឹម២អណត្តិឬ១០ឆ្នាំប៉ុណ្ណោះ។

៣. រូបមន្តដែលល្អបំផុតពិភពលោកធ្លាប់ពិសោធន៏កន្លងមកគឺការធ្វើអោយមានការចូលរួមនយោបាយពីសំណាក់ប្រជាជនអោយបានច្រើនដោយបង្កើតអោយមានប្រព័ន្ឋនយោបាយពហុបក្សនិងសង្គមស៊ីវិល ហើយដើម្បីទប់ស្កាត់មនុស្សខូចប្រើអំណាចខុសនិងពុករលួយ តុលាការត្រូវតែឯករាជ្យ។

៤. រៀបចំប្រព័ន្ឋផ្សព្វផ្សាយដូចជាកាសែត វិទ្យុ ទូរទស្សន៏ និងការសរសេរនិពន្ឋជាដើម ត្រូវតែមានឯករាជ្យនិងអព្យាក្រិត ដែលជាចលករសំខាន់បង្រៀនអោយមហាជនមើលឃើញតថភាពជាក់ស្តែងរបស់សង្គម ហើយសច្ចភាពពិតនោះហើយដែលអាចរក្សាជាតិកម្ពុជាបានគង់វង្សពិតប្រាកដ។ អំពើវិទ្ធង្សនា អាក្រក់ជាល្អ សជាខ្មៅ ខុសជាត្រូវ ពិតជាក្លែង គឺជាមេរោគសំឡាប់ខ្លួនឯង សំឡាប់ក្រុមគ្រួសារ និងប្រទេសជាតិទាំងមូល។

៥. គាំទ្រមតិទាំង៤ខាងលើ

៦. មតិរបស់អ្នកផ្ទាល់.........................................................................
.................................................................................................
.................................................................................................
.................................................................................................
.................................................................................................